**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីរបស់លោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ២៩ខែ កក្កដា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2016, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ (កោសលុប)

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**សំណើលើកទីប្រាំរបស់ នួន ជា សុំកោះហៅសាក្សីនៅក្នុងសំណុំរឿង ០០២/០២ សម្រាប់វគ្គសវនាការស្ដីពីមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" (ភ័ស្តុតាងអំពីការបះបោរក្បត់ ការចាប់ខ្លួនតាមអំពើចិត្ត និង មន្ទីរសន្តិសុខ ស-២១)**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្ដី នួន ជា÷**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
Doreen CHEN
ព្រុំ ផល្លា
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
ឌី សុជាតា

**ផ្ញើជូន÷**

**សហមេធាវីរបស់ ខៀវ សំផន÷**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី÷**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") ដាក់សំណើនេះ ("សំណើ") សុំស្តាប់សក្ខីកម្មសាក្សីថ្មីចំនួនដប់មួយនាក់ ដែលអាចផ្តល់ភ័ស្តុតាងពាក់ព័ន្ធនឹងបញ្ហាដែលរងការជំទាស់សំខាន់ៗនៅក្នុងវគ្គសវនាការស្តីពីមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ ។ មេធាវីការពារក្តីស្នើសុំបន្ថែមទៀតឱ្យទទួលយកធ្វើជាភ័ស្តុតាងនូវចម្លើយសាក្សីចំនួនប្រាំ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងសាក្សីដែលបានស្នើឡើងទាំងនេះ ("ឯកសារ")[1]។

## II. សាវតារ និង ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះមនុស្សចំនួនប្រាំបួននាក់ដំបូងដែលត្រូវកំណត់ឱ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះក្នុងនាមជាសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១[2]។ បុគ្គលទាំងអស់នោះបានចូលមកផ្តល់សក្ខីកម្ម។ នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះមនុស្សចំនួនដប់នាក់ ដែលត្រូវកំណត់ឱ្យចូលមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងវគ្គសវនាការស្តីពី "ការបោសសំអាតផ្ទៃក្នុង"[3]។ នៅក្នុងចំណោមនោះមានម្នាក់ជាសាក្សីរបស់មេធាវីការពារក្តី ហើយដែលបានស្លាប់នៅពីរបីថ្ងៃនៅមុនពេលមកផ្តល់សក្ខីកម្ម និងមួយរូបទៀតមិនអាចទាក់ទងបាន[4]។ មកដល់ពេលនេះ បុគ្គលបួនរូបបានចូលមកផ្តល់សក្ខីកម្ម (ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប និងសាក្សីពីររូប និងអ្នកជំនាញមួយរូប)។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានដាក់សំណើលើកទីមួយសុំកោះហៅសាក្សីសម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខ និង "ការបោសសំអាតផ្ទៃក្នុង" ដោយស្នើសុំឱ្យកោះហៅសាក្សីចំនួនប្រាំមួយនាក់ដែលសក្ខីកម្មរបស់ពួកគាត់ ទាក់

---

[1] ដើម្បីងាយស្រួលដល់អង្គជំនុំជម្រះ និងភាគី ឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី ត្រូវបានដាក់ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម។

[2] ឯកសារ **E391.1.1** សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៦។

[3] អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគី ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦(**ឯកសារភ្ជាប់ ១**)។

[4] សារអេឡិចត្រូនិចរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងជូនភាគី ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ **(ឯកសារភ្ជាប់ ២)**។

ទិននឹងភូមភាគឧត្តរដែលមានទំនាក់ទំនងជាមួយនឹងកងពល ៣១០[5]។ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើលើកទីពីរសុំកោះហៅសាក្សីសម្រាប់វគ្គសវនាការនេះ ដោយស្នើសុំកោះហៅសាក្សីចំនួនប្រាំបីនាក់ដែលភ័ស្តុតាងរបស់ពួកគាត់ទាក់ទិននឹងការដឹកនាំការបះបោរផ្ទៃក្នុងប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា[6]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើលើកទីបីសុំកោះហៅសាក្សីសម្រាប់វគ្គសវនាការនេះ ដោយស្នើសុំឱ្យអង្គជំនុំជម្រះពន្លឿនការចូលមកផ្តល់សក្ខីកម្មរបស់សាក្សីចំនួនបួននាក់ និងស្នើសុំឱ្យកោះហៅសាក្សីចំនួនប្រាំពីរនាក់ដែលសក្ខីកម្មរបស់ពួកគាត់ទាក់ទិននឹងចលនាបះបោរនៅក្នុងភូមិភាគពាយ័ព្យ ភូមិភាគបូព៌ា និងភូមិភាគឦសាន[7]។ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើលើកទីបួនសុំកោះហៅសាក្សី ដោយស្នើឱ្យអង្គជំនុំជម្រះពន្លឿនការចូលមកផ្តល់សក្ខីកម្មរបស់បុគ្គលចំនួនប្រាំពីរនាក់ និងកោះហៅសាក្សីថ្មីចំនួនបីនាក់ដែលភ័ស្តុតាងរបស់ពួកគាត់ទាក់ទិននឹងឯកសារនានាដែលបានបន្សល់ទុកពីសម័យនោះ និងដំណើរការនៃមន្ទីរសន្តិសុខ ស-២១[8]។ អង្គជំនុំជម្រះពុំទាន់បានសម្រេចលើសំណើទាំងបួនសុំកោះហៅសាក្សីទាំងនេះទេ។

3. លើសពីនេះទៀត នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយដោយតម្រូវឱ្យមេធាវីការពារក្តីផ្តល់ព័ត៌មានបន្ថែមស្តីអំពីភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់សាក្សីដែលបានស្នើសុំកាលពីមុនទាំងនោះ ទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងជាពិសេសពន្យល់អំពី "ថាតើអត្ថិភាពនៃក្រុមជម្លោះទាំងនោះអាចផ្តល់នូវការការពារខ្លួនចំពោះបទចោទនានានៅក្នុងដីកាដំណោះស្រាយដោយរបៀបណា ឬថាតើ អត្ថិភាពនេះអាចចាត់ទុកថាជាស្ថានសម្រាលដោយរបៀបណា"[9]។ មេធាវីការពារក្តីបានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លើយតប នៅ

---

[5] ឯកសារ **E391** សំណើសុំសាក្សីទីមួយ (កងពល ៣១០) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦។

[6] ឯកសារ **E392** សំណើសុំសាក្សីទីពីរ (ថ្នាក់ដឹកនាំ) ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦។

[7] ឯកសារ **E395** សំណើសុំសាក្សីទីបី (ភ័ស្តុតាងអំពីការបះបោរក្បត់) ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦។

[8] ឯកសារ **E412** "សំណើសុំសាក្សីទីបួន (ដំណើរការមន្ទីរសន្តិសុខ ស-២១ និងភ័ស្តុតាងជាឯកសារ) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦។

[9] ឯកសារ **E395/1** "សំណើសុំសារណាសង្ខេបស្តីអំពីសារៈសំខាន់នៃក្រុមជម្លោះនៅក្នុងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ ERN (ភាសាខ្មែរ) **01240210**។

ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦[10]។

4. ចាប់តាំងពីនោះមក មេធាវីការពារក្ដីបានកំណត់អត្តសញ្ញាណសាក្សីថ្មីចំនួនដប់មួយរូបដែលអាចផ្ដល់ភ័ស្ដុតាង ទាក់ទិននឹងសំណុំរឿងរបស់មេធាវីការពារក្ដីពាក់ព័ន្ធនឹងវគ្គសវនាការស្ដីពីមន្ទីរសន្តិសុខ និង "ការបោសសំអាតផ្ទៃក្នុង"។

## III. ច្បាប់ជាធរមាន

### ក. ការកោះហៅសាក្សីថ្មីៗ និង ការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្ដាប់ចម្លើយ

5. រាល់ភស្តុតាងទាំងអស់ត្រូវបានទទួលយក លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង[11]។ អង្គជំនុំជម្រះអាចបដិសេធសំណើទទួលយកភស្តុតាងក្នុងករណីដែលខ្លួនយល់ឃើញថា ភស្តុតាងមិនមានភាពពាក់ព័ន្ធ ឬក៏ច្រំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនអាចបង្ហាញទៅលើអង្គហេតុដែលខ្លួនអាចបង្ហាញ មិនអនុញ្ញាតដោយច្បាប់ ឬក៏នាំឲ្យពន្យារពេលដំណើរការ ឬក៏មិនមានប្រយោជន៍[12]។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ផ្ដល់សិទ្ធិដល់អង្គជំនុំជម្រះក្នុងការកោះហៅបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សីដែល "មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភាគី។ វិធាននេះតម្រូវឲ្យអង្គជំនុំជម្រះពិចារណាទៅលើសំណើ អនុលោមទៅតាមលក្ខខណ្ឌនានាដែលមានចែងក្នុងវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មនោះពុំអាចរកបាននៅមុនពេលចាប់ផ្ដើមជំនុំជម្រះ[13]។ អង្គជំនុំជម្រះបានសម្រេចថា នៅពេលភាពជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់បុគ្គលម្នាក់ត្រូវបានបង្ហាញ តែមាន "ព័ត៌មានតិចតួច" មុនពេលចាប់ផ្ដើមជំនុំជម្រះ ទោះបីព័ត៌មានពិស្ដារបន្ថែមទៀតអាចរកបានតែក្រោយពេលចាប់ផ្ដើមជំនុំជម្រះក៏ដោយ ក៏សក្ខីកម្មដែលលើក

---

[10] ឯកសារ **E395/2** សេចក្ដីសន្និដ្ឋានរបស់ នួន ជា ស្ដីពីភាពពាក់ព័ន្ធនៃភ័ស្ដុតាងស្ដីពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦។

[11] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[12] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[13] អង្គជំនុំជម្រះបានបញ្ជាក់ថា ការចាប់ផ្ដើមការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ គឺសវនាការបឋម ដែលបានចាប់ផ្ដើមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។

ឡើងនោះនឹងត្រូវបានចាត់ទុកថាពុំអាចរកបានមុនពេលចាប់ផ្តើមជំនុំជម្រះដែរ[14]។ នៅពេលដែលសក្ខីកម្មអាចរកបានមុនពេលចាប់ផ្តើមជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទោះជាយ៉ាងណាក្តី ភស្តុតាងនេះអាចត្រូវបានទទួលយក "នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវ ជាពិសេស ដរាបណាភស្តុតាងទាំងនេះជាភស្តុតាងដោះបន្ទុក ដែលតម្រូវឲ្យធ្វើការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌"[15] ឬ នៅពេលដែលភស្តុតាងនេះ "ទាក់ទងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ... ដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា"[16]។ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវតែមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន *ជាបឋម*[17]។

## ខ. ការស៊ើបសួរបន្ថែម

6. វិធាន ៩៣ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យមានការស៊ើបសួរបន្ថែមនៅក្នុងអំឡុងពេលដំណើរការជំនុំជម្រះ នៅពេលដែលអង្គជំនុំជម្រះ "យល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់"។ ចៅក្រមដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសម្រាប់គោលបំណងនេះ "ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបសួរដែរនោះអាច៖ (ក)ចុះទៅដល់ទីកន្លែងណា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ខ) ស្តាប់ចម្លើយសាក្សី (គ) ដឹកនាំការឆែកឆេរ (ឃ) ចាប់យកវត្ថុតាង ឬ (ង) បង្គាប់ឲ្យ

---

[14] ប្រតិចារឹកសវនាការ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ (សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ឯកសារ E1/363.1) ទំព័រ ៤១ បន្ទាត់ ៦-១០។

[15] ឯកសារ **E307/1** "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ **E307**) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ **E305/3**)" ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣ *ស្របនឹង* ឯកសារ **E190** "សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត" ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើឯកសារថ្មីៗ") កថាខណ្ឌ ៣៦។

[16] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ **E289**) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)" ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣ *ស្របនឹង* ឯកសារ E190 សេចក្តីសម្រេចលើឯកសារថ្មីៗ កថាខណ្ឌ ៣២។

[17] ឯកសារ **E313** "សាលក្រមក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៦។

ធ្វើកោសលវិច័យ"។

7. ផ្អែកលើយុត្តិសាស្ត្រមុនៗរបស់អង្គជំនុំជម្រះនេះ ភាពចាំបាច់ក្នុងការផ្តួចផ្តើមឲ្យមានការស៊ើបសួរថ្មី៖

> ត្រូវតែសំអាងលើផលប្រយោជន៍យុត្តិធម៌។ ដូចគ្នាដែរ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែឲ្យគេយល់បាននៅក្នុងបរិបទក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយប្រធានសវនាការមានឆន្ទានុសិទ្ធិក្នុងការបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ[18]។

## IV. ទឡ្ហីករណ៍

### ក. អំណះអំណាងរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីមន្ទីរសន្តិសុខ និង ការបោសសំអាត ផ្ទៃក្នុង

### *(i) ការបះបោរក្បត់ និងវៀតណាម*

8. ដូចដែលមេធាវីការពារក្តីបានពន្យល់យ៉ាងលម្អិតរួចហើយនៅក្នុងសំណើជាច្រើនដែលបានដាក់កាលពីមុននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[19] ចំណុចស្នូលនៃអំណះអំណាងរបស់មេធាវីការពារក្តីនោះគឺថា បក្សកុម្មុយនីស្តកម្ពុជា មិនត្រឹមតែ

---

[18] ឯកសារ **E294/1** "សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភស្តុតាងថ្មី, ឲ្យចាប់ផ្តើមការស៊ើបអង្កេត និងឲ្យកោះហៅលោក Rob LEMKIN" ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។

[19] ឯកសារ **E370** "សំណើបន្ទាន់ និងរួមគ្នារបស់ នួន ជា សុំឲ្យពន្លឿនសំណើពីររបស់ខ្លួនដែលបានស្នើរួចហើយ និងសុំឲ្យកោះហៅសាក្សីបន្ថែមបួនរូប ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើសុំសាក្សីភូមិភាគបូព៌ា") កថាខណ្ឌ ២៥។ ឯកសារ **E395/2** សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាងស្តីពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ("សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាងនៃការបះបោរក្បត់") ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦។ សូមមើល ផងដែរ ឯកសារ E370 "សំណើបន្ទាន់ និងរួមគ្នារបស់ នួន ជា សុំឲ្យពន្លឿនសំណើពីររបស់ខ្លួនដែលបានស្នើរួចហើយ និងសុំឲ្យកោះហៅសាក្សីបន្ថែមបួនរូប ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើសុំសាក្សីភូមិភាគបូព៌ា") កថាខណ្ឌ ២៥។ *សូមមើល ផងដែរ* ឯកសារ **F2/8** "សំណើទី៦ របស់ នួន ជា ស្នើសុំឲ្យមានការពិចារណា និងទទួលយកបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ២៣-៦៩។

មិនមានឋានានុក្រម "រាងពីរ៉ាមីត" មិនមានវិន័យ និងមិនមានការឯកភាពគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងហ៊ុមព័ទ្ធទៅដោយភាពចលាចលផ្ទៃក្នុងជាប្រចាំ ហើយក្រុមផ្សេងៗដែលមានកម្លាំងខ្លាំងស្មើគ្នា (រួមទាំងក្រុមមួយដែលដឹកនាំដោយលេខាភូមិភាគបូព៌ា សោ ភឹម និងលេខាភូមិភាគពាយ័ព្យ រស់ ញឹម) បានអនុវត្តកម្មវិធីប្រណាំងប្រជែងមួយក្នុងគោលបំណងដណ្តើមគ្រប់គ្រងបក្ស និងប្រទេសទាំងមូល ហើយក្រុមមួយក្នុងចំណោមក្រុមទាំងនេះក៏ព្យាយាមសម្រេចផលប្រយោជន៍ យ៉ាងហោចណាស់សម្រាប់វៀតណាម បើមិនមែនសម្រាប់សហភាពសូវៀតទេនោះ។ ក្រុមនេះបានទទួលជំនួយជាច្រើនពីវៀតណាមដើម្បីជំរុញអំពើបះបោរ និងអំពើក្បត់ប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ និងស្របច្បាប់ ចាប់តាំងពីពេលរំដោះទីក្រុងភ្នំពេញភ្លាមៗនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

### *(ii)* ការចាប់ខ្លួនតាមតែទំនើងចិត្ត

9. ការពិពណ៌នាអំពីព្រឹត្តការណ៍នានាដែលបានកើតឡើងនៅក្នុងពេលវេលាសំខាន់នោះ គឺពាក់ព័ន្ធទៅនឹង *ក្នុងចំណោមប្រការផ្សេងទៀត* ការដឹងឮរបស់ នួន ជា អំពីឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានចោទប្រកាន់នៅក្នុងតំបន់នានាដែលគ្រប់គ្រងដោយក្រុមប្រឆាំង និងការគ្រប់គ្រងរបស់គាត់ទៅលើចារីដែលជាសមាជិករបស់ក្រុមប្រឆាំង។ លើសពីនេះទៀត ភ័ស្តុតាងបែបនេះ មានឥទ្ធិពលផ្ទាល់ទៅលើការវាយតម្លៃអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ក្រោមទម្រង់នៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងតំបន់ទាំងនោះ[20]។

10. ភ័ស្តុតាងបែបនេះក៏អាចគាំទ្រផងដែរដល់អំណះអំណាងរបស់មេធាវីការពារក្តីដែលថា ការចាប់ខ្លួន និងការឃុំខ្លួនជាច្រើនមិនមែនធ្វើឡើងតាមទំនើងចិត្តទេ ប៉ុន្តែធ្វើឡើងដោយផ្អែកលើការសង្ស័យដ៏ត្រឹមត្រូវអំពីអំពើក្បត់ និងចារកិច្ច[21]។

---

[20] *សូមមើល ឯកសារ* **E395/2** សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភ័ស្តុតាងស្តីពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ EN 01251283-86 កថាខណ្ឌ ៣៥-៣៨។

[21] *សូមមើល ឯកសារ* **E395/2** សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភ័ស្តុតាងស្តីពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ERN (ភាសាខ្មែរ) 01251321-27, *សំណើលើកទីប្រាំរបស់ នួន ជា សុំកោះហៅសាក្សី*

### *(iii) ចំនួនអ្នកស្លាប់នៅ ស-២១*

11. ដោយពឹងផ្អែកទាំងស្រុងទៅលើភស្តុតាងដែលផ្តល់ដោយ ឌុច ដីកាដំណោះស្រាយចោទប្រកាន់ថា៖

> អ្នកជាប់ឃុំជាង ១២ ២៧៣ នាក់ ដែលមានសមាសភាពត្រូវបានរៀបរាប់ពីខាងលើ ត្រូវបានសម្លាប់ចោល នៅជើងឯក ខាងក្នុង ឬជិតបរិវេណមន្ទីរ ស២១។ នៅក្នុងសាលក្រមសាលក្រម ឌុច អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា *"ផ្អែកតាមគោលនយោបាយក្នុងការ "កម្ទេច" ខ្មាំងនៃបក្សកុម្មុយនិស្តកម្ពុជា អ្នកជាប់ឃុំទាំងឡាយដែលបានជាប់ឃុំនៅមន្ទីរ ស២១ ត្រូវតែសម្លាប់ទាំងអស់ គ្មានអ្នកជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឡើយ"*។ ឌុច បានអះអាងថា ការសម្លាប់អ្នកទោសណាម្នាក់អាចធ្វើឡើងតាមការណែនាំពីថ្នាក់លើ ជាពិសេសចំពោះការសម្លាប់ទ្រង់ទ្រាយធំ ឬផ្អែកតាមការសម្រេចចិត្តដោយឯកឯងរបស់គាត់ ដោយអនុវត្តតាមមាគ៌ានយោបាយជាទូទៅរបស់បក្ស ដែលមានគោលដៅសម្លាប់អ្នកទោសចោល ទាំងអស់[22]។

12. ផ្ទុយទៅវិញ ដោយពឹងផ្អែកទៅលើប្រភពផ្សេងៗ[23] ជំហររបស់មេធាវីការពារក្តីគឺថា ភាគច្រើននៃបុគ្គលដែលចុះបញ្ជីនៅមន្ទីរស២១ គឺមិនចាំបាច់ត្រូវបានឃុំឃាំងនៅបរិវេណស២១នោះទេ ហើយក៏មិនត្រូវបានសម្លាប់ជាប្រព័ន្ធនោះដែរ។ តាមពិតបុគ្គលជាច្រើនដែលមាននៅក្នុង "បញ្ជីអ្នកទោស ស២១" គឺត្រូវបានចុះឈ្មោះនៅ ស២១ នៅភ្នំពេញ ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅកន្លែង

---

កថាខណ្ឌ ៣៤-៣៨។ *សូមមើល ឯកសារ* **E395/2** សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាងស្តីពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ERN (ភាសាខ្មែរ) 01251321-27, កថាខណ្ឌ ១៨-២៣។

[22] **D427** ដីកាដំណោះស្រាយ កថាខណ្ឌ៤៦០-៤៦១ សូមមើល **D427** ដីកាដំណោះស្រាយ លេខជើងទំព័រ ២០០០។

[23] សូមមើល E3/8639 "5186 រូបថតរបស់អ្នកទោស ស-២១ ពីការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨ **E3/1684** សម្លេងពីមន្ទីរ ស-២១ ដោយ ដេវីឌ ឆេនដល័រ ឆ្នាំ១៩៩៩ ភាសាអង់គ្លេស ០០១៩២៦៧៦-៧៧ (ដេវីឌ ឆេនដល័រ សំដៅលើការរកឃើញហ្វីលរូបថតចំនួន៦០០០ នៅមន្ទីរ ស-២១) ភាសាអង់គ្លេស ០០១៩២៦៨៥ និង ០០១៩២៦៩១ (ដេវីដ ឆេនដល័រសំដៅលើចម្លើយសារភាពចំនួន៤៣០០ រកឃើញនៅមន្ទីរស- ២១ បន្ទាប់ពីរបបត្រូវដួលរលំ និងមួយចំនួន ធំទៀតនៅអំឡុងឆ្នាំ១៩៩៥) **E3/7325** របាយការណ៍របស់ Geng Biao ស្តីពីស្ថានភាពនៃឧទ្វីបឥណ្ឌូចិន ឆ្នាំ១៩៧៩ ភាសាអង់គ្លេស ០១០០១៦២២ (Geng Biao ក្រោយមកអគ្គលេខាធិការនៃគណៈកម្មាធិការយោធារបស់បក្សកុម្មុយនីស្តចិន បាននិយាយថា ក្នុងខែមករា ឆ្នាំ១៩៧៩ "មនុស្ស៤០០០នាក់ បើមិនស្លាប់ គឺត្រូវដាក់គុក" **E393.2** បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៦ (ឈ្មោះ ៥៥១២ គឺជា បញ្ជី ដែល មាន បញ្ជាក់ ពីកាលបរិច្ឆេទសម្លាប់) **E404/4/2.2** លលាដ៏ក្បាលលដោយ"លលាដ៏ក្បាល,ក្រុមការងារធ្វើបញ្ជីការសម្លាប់របស់ខ្មែរក្រហម" ការសែត ខេមបូឌា ដេលី ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៦ (ការបន្តធ្វើការស្រាវជ្រាវវិភាគលើលលាដ៏ក្បាលចំនួន៦៤២៦ នៅជើងឯក)។

ផ្សេងៗទៀត ដូចជា ព្រៃស[24] ឬ ព្រលានយន្តហោះកំពង់ឆ្នាំង[25] ឬក៏ត្រូវបានដោះលែង[26]។ អាស្រ័យហេតុនេះហើយ មេធាវីការពារក្តីសូមលើកឡើងថា ចំនួនអ្នកទោសដែលត្រូវបានឃុំនៅ ស២១ គឺមានតែពី ៥ ០០០ ទៅ ៦ ០០០ នាក់ប៉ុណ្ណោះ។

## ក. សាក្សីថ្មីពីរនាក់ផ្តល់សក្ខីកម្មអំពីក្រុមជម្លោះផ្ទៃក្នុងនៅក្នុងភូមិភាគពាយ័ព្យ នាក់ទិននៅនឹងវគ្គសវនាការស្តីពី "ការបោសសំអាតផ្ទៃក្នុង"

### *(i) សាក្សី៤*

13. [redacted]ះ

[redacted]

---

[24] **E3/7639** កំណត់ហេតុស្តាប់បម្លើយសាក្សី នឹម គឹមស្រ៊ាង ភាសាអង់គ្លេស ០០១៦២៧៣៣-២៧៣៤, ០០១៦២៧៣៦ **E3/7664** កំណត់ហេតុស្តាប់បម្លើយសាក្សី សុខ សុផាត ភាសាអង់គ្លេស ០០១៦៣៨០៤ **E3/7543** បទសម្ភាសន៍ ឌី ស៊ី ខេម ជាមួយតុប វី ភាសាអង់គ្លេស ០០៣២៤២៧៤-៧៥។

[25] មើលឧទាហរណ៍ **E3/7532** បទសម្ភាសន៍ ឌី ស៊ី ខេម ជាមួយ [redacted] ភាសាអង់គ្លេស ០០៣២៩៤៧៨។

[26] មើលឧទាហរណ៍ **E393.2** បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៦។ លេខ ៧៣៩០, ៧៣៩៦, ៧៣៩៧, ៧៣៩៩, ៧៤០៥, ៧៤០៦, ៧៤០៩, ៧៤១២, ៧៤២១, ៧៤៤៣, ៧៤៤៥, ៧៤៥០, ៧៤៥៣, ៧៤៦០, ៧៤៦៩, ៧៤៧៥, ៧៤៧៩។

[27] [redacted]។

[redacted]

[redacted]

[redacted]។

14. [redacted]

---

28 [redacted]

29 [redacted]

30 [redacted]

31 [redacted]។

[redacted]៖

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]។

15. **វិធានការការពារ**៖ សក្ខីកម្មរបស់សាក្សី៤ មិនត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅរបស់ ថេត សម្បត្តិ ឡើយ[33] ហើយបុគ្គលរូបនេះបានស្នើសុំឱ្យរក្សាការសម្ងាត់បំផុត[34]។ ទោះបីជាយ៉ាងណាក៏ដោយ ក្របខណ្ឌ អ.វ.ត.ក ផ្តល់នូវវិធានការច្រើនប្រភេទដើម្បីធានានូវការការពារ និងរក្សាការសម្ងាត់ពេញលេញដល់សាក្សីសំខាន់ៗ "ដែលការបង្ហាញខ្លួនរបស់ពួកគាត់នៅចំពោះមុខអង្គជំនុំ

---

32 [redacted]។

33 ឯកសារ **E3/4202** សៀវភៅនិពន្ធដោយ Gina Chon និង ថេត សម្បត្តិ មានចំណងជើងថា នៅពីក្រោយវាលពិឃាត (Behind the Killing Fields) ឆ្នាំ 2010។

34 [redacted]។

ជម្រះ អាចធ្វើឲ្យជីវិត ឬសុខភាពរបស់ពួកគាត់ ឬរបស់សមាជិកគ្រួសាររបស់ពួកគាត់ ឬសាច់ញាតិជិតស្និទ្ធរបស់ពួកគាត់ស្ថិតក្រោមគ្រោះថ្នាក់ធ្ងន់ធ្ងរ"[35]។ ដូច្នេះ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះស្នើទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្វើការវាយតម្លៃពីហានិភ័យ អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង និងផ្តល់នូវវិធានការការពារបន្ថែមទៀតដែលយល់ឃើញថាចាំបាច់ដើម្បីអាចឲ្យគាត់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

***(ii) [redacted] (2-TCW-971)***

16. [redacted] (2-TCW-971) មានតួនាទីជាអនុប្រធានផ្នែកពាណិជ្ជកម្មក្នុងស្រុកត្រាំកក់ ចាប់ពីដើមឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៨[36]។ ក្រោយមកទៀត គាត់ក៏ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅក្នុងភូមិភាគពាយ័ព្យ ដើម្បីជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនឲ្យបានប្រសើរឡើង។ ការរៀបរាប់របស់គាត់អំពីស្ថានភាពដែលគាត់បានជួបប្រទះនៅពេលទៅដល់ភូមិភាគពាយ័ព្យនោះ ស៊ីសង្វាក់គ្នាជាមួយនឹង ការរៀបរាប់របស់ អៀង ធិរិទ្ធ[37] និង [redacted][38]៖

> ឆ៤៖ គេឲ្យទៅនៅស្រុកដូនទាវ គឺទៅមើលកន្លែងគេធ្វើបាបមនុស្ស។ [...] តាទីថាយ បានបញ្ជាឲ្យខ្ញុំទៅមើលការខុសត្រូវនៅដូនទាវ ព្រោះមានគេបម្រុងនឹងសម្លាប់មនុស្សនៅក្នុងសហករណ៍។ គេឲ្យខ្ញុំទៅជួយដោះស្រាយបញ្ហាស្បៀង និងសម្រាលការងារចំពោះអ្នកដែលកំពុងអត់ឃ្លាន [...] បន្ទាប់មកមានព្រឹត្តការណ៍កើតឡើងនៅថ្មគោល គេក៏បានបញ្ជូនខ្ញុំទៅថ្ម គោលទៀត។ ព្រឹត្តការណ៍កើតឡើង

---

[35] សូមមើល ឯកសារ **E293** សេចក្តីសម្រេចលើសំណើសុំវិធានការការពារទាំងអស់នៅក្នុងសំណុំរឿង ០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ (ឯកសារ **E286**) ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ ERN (ភាសាខ្មែរ) **00933647-48** កថាខណ្ឌ ៦-៧។ សូមមើលផងដែរ វិធាន ២៩ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩)។

[36] ឯកសារ **E3/9593** "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted]" ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ERN (ភាសាខ្មែរ) 00968030 ឆ១។

[37] **E3/659** បទសម្ភាសន៍របស់ អៀង ធិរិទ្ធ ជាមួយ Elisabeth Becker, EN 00182322-23។

[38] [redacted]។

នៅពេលនោះ គឺដោយសារអ្នក ១៧ មេសា និងអ្នកនៅក្នុង កងចល័តដែលធ្វើការនៅម្ដុំវាលទ្រា ពួកគេអត់បាយហូប និងខ្លះទៀតឈឺ។ គេក៏ឱ្យខ្ញុំទៅជួយដោះស្រាយរកអ្វីឱ្យពួកគេហូប[39]។

ឆ២២៖ [...] តាម៉ុក [...] បាននិយាយថា សភាពការណ៍នៅភូមិភាគពាយ័ព្យមិនល្អទេ ដូច្នេះ ត្រូវការជ្រើសរើសមនុស្សយកទៅជួយ។

ឆ២៣៖ ប្រជាពលរដ្ឋខ្លះបាយហូប។ មានការបែងចែកប្រជាពលរដ្ឋជាពីរបីផ្នែក។ ថ្នាក់ដឹកនាំខ្លះមានទំនាស់គ្នា ហើយប្រជាពលរដ្ឋមានការលំបាក។ អ្នកខ្លះទៀតនៅជាប់ក្នុងមន្ទីរឃុំឃាំងជាដើម [...]។

ឆ៦៣៖ [...] នេះហើយគឺជាមូលហេតុដែលគេបញ្ជូនពួកខ្ញុំទៅមើលថាអ្នកណាខ្លះឱ្យប្រជាជនធ្វើការហួសកម្លាំង ហូបមិនឆ្អែតជាដើម៖ យើងទៅលុបបំបាត់នូវអំពើទាំងអស់នោះ។ ប៉ុន្តែយើងមិនទាន់ទាំងបានធ្វើផងវៀតណាមក៏មកដល់។ ពេលដែលយើងទៅដល់ភូមិភាគពាយ័ព្យ យើងបានឃើញអង្ករដែលគេស្តុកទុកចោល ខោអាវត្រូវពុកផុយ ស្តុកទុកចោល។ ពួកគេបានធ្វើរបាយការណ៍ថា ស្បៀងនៅសល់ ទាំងស្រូវ ទាំងអង្ករ ប៉ុន្តែនៅពេលដែលយើងទៅដល់គឺនៅសល់មែន ប៉ុន្តែប្រជាជនអត់បាយ។ បាត់ដំបងជាខេត្តដែលសម្បូរស្រូវ ប៉ុន្តែហេតុអ្វីបានជាប្រជាជនអត់បាយ។ ដោយហេតុនេះ ខ្ញុំយល់ឃើញថា ប្រាកដជាមានពួកចង់ដុតឱ្យខ្លោចរោលឱ្យឆៅ"។

17. ដូច្នេះ មេធាវីការពារក្តីអះអាងថា [redacted] (2-TCW-971) អាចផ្តល់នូវការយល់ដឹងដ៏សំខាន់ និងពិសេស ពាក់ព័ន្ធនឹងផលវិបាកនៃគោលនយោបាយនានាដែលបានអនុវត្តឡើងដោយអតីតកម្មាភិបាលភូមិភាគពាយ័ព្យ ស្តីអំពីស្ថានភាពរស់នៅរបស់ប្រជាជន, ភាពខុសគ្នារវាងគោលនយោបាយទាំងនោះ និងមាគ៌ាបក្ស, សេចក្តីណែនាំដែលគាត់ទទួលបានពីមជ្ឈិមបក្សដើម្បីកែលម្អស្ថានភាពឱ្យបានឆាប់រហ័ស និង "ការបោសសំអាត" ដែលបានកើតឡើងនៅក្នុងភូមិភាគនោះ។

## ខ. សាក្សីថ្មីប្រាំនាក់នឹងត្រូវផ្តល់សក្ខីកម្មអំពីការបះបោរក្បត់ដោយកម្មាភិបាលភូមិភាគបូព៌ា

### *(i) [redacted] (សាក្សី ក)*

18. [redacted] (សាក្សី ក) គឺជាពេទ្យនៅក្នុងកងពល ៧០៣។ គាត់ពិពណ៌នាអំពីព្រឹត្តការណ៍ដែលបានកើតឡើងនៅក្នុងឆ្នាំ ១៩៧៥ នៅពេលដែលហៀបនឹងមានជម្លោះរវាងភូមិភាគបូព៌ា និងភូមិភាគនិរតី នៅក្នុងអំឡុងបុណ្យខួបបក្សនៅស្តាតអូឡាំពិក។ គាត់បានបញ្ជាក់បន្ថែមទៀតថា

---

[39] ឯកសារ E3/9593 "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted]" ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ERN (ភាសាខ្មែរ) 00968030 ឆ៩។

ថ្នាក់ លើបានទប់ទល់ទាន់ពេល[40]។ គាត់ពិពណ៌នាដ៏គួរឲ្យចាប់អារម្មណ៍ទៀតអំពី "ការបះបោរ" រវាងភូមិភាគនិរតី ដែលគាំទ្រ ប៉ុល ពត និងភូមិភាគបូព៌ានៅក្នុងឆ្នាំ ១៩៧៧ និងប្រាប់ឲ្យដឹងថា ការវាយប្រយុទ្ធគ្នានោះ គឺមានបំណង "ដណ្តើមប្រទេសហ្នឹង...ដណ្តើមកាន់អំណាចហ្នឹង"[41]។

***(ii)*** [redacted] ***(សាក្សី ខ)***

19. [redacted] ***(សាក្សី ខ)*** គឺជាទាហានម្នាក់នៅក្នុងកងវរសេនាតូច ១២៧ ក្នុងកងកាំភ្លើងធំនៃកងពល ៧០៣។ គាត់ផ្តល់ភ័ស្តុតាងអំពីអត្ថិភាពនៃជម្លោះផ្ទៃក្នុង នៅត្រឹមខែ មេសា ឆ្នាំ ១៩៧៦។ តាមពិត ខណៈដែលគាត់ត្រូវបានគេចាត់ឲ្យទៅឈរការពារនៅស្តាតអូឡាំពិកក្នុងអំឡុងបុណ្យខួបជ័យជម្នះ ក្នុងឆ្នាំ ១៩៧៦ នោះ គាត់ត្រូវបានគេបញ្ជាឲ្យទៅការពារមនុស្សទប់ទល់នឹងការវាយប្រហារពីសំណាក់ សោ ភឹម៖

> បុណ្យខួបជ័យជម្នះ។ មានការបែកបាក់ជាមួយពួកបូព៌ា។ គេថា ពួក សោ ភឹម រៃចូលទៅស្តាតអូឡាំពិក ដូច្នេះគេបំបែកទ័ពក្នុងស្តាតអូឡាំពិកទៅឲ្យការពារនៅខាងក្រៅវិញ ព្រោះថាមានពួកក្បត់ចង់រៃបំបែកយើងមូលម៉ុចឹង[42]។

20. លើសពីនេះទៀត [redacted] (សាក្សី ខ) បញ្ជាក់ថា បន្ទាប់ពីគាត់ចប់ភារកិច្ចយាមកាមនៅក្នុងទីក្រុងភ្នំពេញហើយនោះ គាត់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅព្រៃស រយៈពេលពី ៥ ទៅ ៦ ខែ នៅក្នុងឆ្នាំ ១៩៧៥[43]។ ដូច្នេះ គាត់អាចផ្តល់ការពិពណ៌នាដ៏គួរឲ្យចាប់អារម្មណ៍អំពីការដ្ឋានការងារព្រៃស (ស-២៤)។

***(iii)*** [redacted] ***(សាក្សី គ)***

21. [redacted] (សាក្សី គ) គឺជាទាហានម្នាក់ក្នុងកងពល ៧០៣។ ដោយសារគាត់ឈរជើងនៅភូមិភាគបូព៌ា គាត់ផ្តល់ការពិពណ៌នាដ៏គួរឲ្យចាប់អារម្មណ៍អំពីការឈ្លានពានរបស់វៀតណាមចូលក្នុងទឹកដី

---

[40] "បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ [redacted] (សាក្សី ក)" ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១ ("បទសម្ភាសន៍របស់ DC-Cam ជាមួយ [redacted] (សាក្សី ក)") ERN (ភាសាខ្មែរ) 01247819។

[41] ("បទសម្ភាសន៍របស់ DC-Cam ជាមួយ [redacted] (សាក្សី ក)") ERN (ភាសាខ្មែរ) 01247818.

[42] "បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ [redacted] (សាក្សី ខ)" ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១ ("បទសម្ភាសន៍របស់ DC-Cam ជាមួយ [redacted] (សាក្សី ខ)") ERN (ភាសាខ្មែរ) 01247678។

[43] បទសម្ភាសន៍របស់ DC-Cam ជាមួយ [redacted] ERN (ភាសាខ្មែរ) 01247681។

កម្ពុជានៅត្រឹមឆ្នាំ ១៩៧៦ និងអំពីចលាចលបន្តបន្ទាប់មកទៀតដែលបានញាំញីភូមិភាគបូព៌ា។ គាត់ពិពណ៌នាអំពីការវាយប្រយុទ្ធគ្នាដែលបានកើតឡើងរវាងអង្គភាពមួយនៃកងពល ៧០៣ ប្រឆាំងនឹងពួកបះបោរភូមិភាគបូព៌ា ក្នុងគោលបំណងដើម្បីបង្ក្រាបកម្លាំងបះបោរដែលបានចូលរួមជាមួយនឹងវៀតណាម[44]។

[redacted] ជំនាន់នោះ គេចោទថាខាងភូមិភាគបូព៌ាចូលដៃចូលជើងជាមួយយួន។ មានរត់រួចទៅច្រើនណាស់ ដូចអ៊ុំ ហេង សំរិនក៏គាត់រត់ទៅរួចដែរ។

វណ្ណ: ហេង សំរិន គាត់មានតួនាទីអីដែរ?

[redacted] កាលហ្នឹងគាត់ជាកងពល។

វណ្ណ: ពូមានដែលស្គាល់ឃើញគាត់ដែរ?

[redacted] អត់មានដែលឃើញទេ គាត់នៅផ្ទះយាយ (យាយហ៊ី)នេះ។

វណ្ណ: ពីណាគេដឹកនាំនៅបូព៌ាណឹង?

[redacted] ជំនាន់នោះគឺខាងសោភឹម តាហេង សំរិន។ សោ ភឹម ខ្ញុំឮសូរដូចជាចាប់ ចាប់ពួក ចាន់ ចក្រី[45]។

*(iv)* [redacted] *(សាក្សី ឃ)*

22. [redacted] (សាក្សី ឃ) គឺជាប្រធានកងកុមារនៅក្នុងកងពលធំ ៧០៣។ យោងតាមកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់អាចផ្តល់ភ័ស្តុតាងសំខាន់ និងពិសេសអំពីអំពើក្បត់របស់ចាន់ចក្រី និងការចាប់ខ្លួនជាបន្តបន្ទាប់។ ជាក់ស្តែង គាត់បានលើកឡើងនៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាថា៖

> ខ្ញុំឮសូរថា[៧០៣]ចាប់បានគេអូររបស់ចាន់ចក្រីខាងបូព៌ាគឺចាប់គេអូរបានក្នុងឆ្នាំ៧៦។ ឮសូរថា គេអូរ ចាន់ចក្រីនិយាយថា "គេជិតឆ្លងទន្លេរួចហើយ"។ ប៉ុន្តែ ខ្ញុំពួតគេដែរទេ ខ្ញុំមិនបានឮផ្ទាល់ត្រចៀកខ្ញុំទេព្រោះមិនមែនតួនាទីយើងអ្នកកាន់អាណឹងណា ព្រោះយើងចប់សង្គ្រាមហើយគេដកសិទ្ធិយើង គឺយើងកាន់តែអូរតែនៅក្នុងសមរភូមិតែម៉ាពេលហ្នឹងទេ។ ដល់តែថា "ជិតឆ្លងទន្លេរួចហើយ" ក៏មានបញ្ជាមួយចាប់កងបូព៌ាណឹងយកមកធ្វើបាបយកទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង[46]។

---

44 បទសម្ភាសន៍របស់ DC-Cam ជាមួយ [redacted] ERN (ភាសាខ្មែរ) 01247763 (បកប្រែផ្ទៃក្នុង)។

45 បទសម្ភាសន៍របស់ DC-Cam ជាមួយ [redacted] ERN 01247763 (ភាសាខ្មែរ) 01161113។

46 "កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារជាមួយនឹង [redacted]" ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ ("កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted]") ERN 01247901។

23. បន្ថែមលើការរៀបរាប់ពិសេសអំពីកាលៈទេសៈជុំវិញការចាប់ខ្លួន ចាន់ចក្រី [redacted] (សាក្សី ឃ) អាចផ្ដល់ភ័ស្តុតាងពិសេសពាក់ព័ន្ធនឹងជើងឯកក្នុងលក្ខណៈទូទៅ និងការប្រព្រឹត្តិលើកុមារនៅទីនោះ ដោយហេតុថា មានពេលមួយនោះ គាត់ត្រូវបានគេបញ្ជូន និងចាត់តាំងឲ្យមើលថែទាំ និងបង្រៀនកុមារ៖

> ទៅទាំងកុមារទៅទាំងកងទ័ពណឹង [ធ្វើស្រែ]។ [...]។ តែនៅក្ដាប់កុមារ។ ទៅដល់ជើងឯកណឹងក៏វរសេនាធំគាត់ចាត់តាំងឲ្យខ្ញុំបង្រៀនកុមារណឹងអក្សរថែមទៀត[47]។

***(v) [redacted] (សាក្សី ង)***

24. យោងតាម [redacted] (2-TCW-831) [redacted] (សាក្សី ង) គឺជាមេដឹកនាំកងវរសេនាតូចនៅក្នុងក្រុមបះបោរនៃភូមិភាគបូព៌ា[48]។ ម្យ៉ាងវិញទៀត [redacted] (សាក្សី ង) ក៏ត្រូវបានគេលើកឡើងថាជាបុគ្គលម្នាក់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំមួយដែលមាន [redacted] (2-TCW-831) ហ៊ុន សែន (2-TCW-1001) និង ជា ស៊ីម ចូលរួមផងដែរ។ កិច្ចប្រជុំនេះបានធ្វើឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ នៅមេមត់ ដោយមានគោលបំណងបង្កើតផែនការ "កំទេចយុទ្ធជនភូមិភាគបូព៌ា" និង "រត់គេចខ្លួនទៅប្រទេសវៀតណាម"[49]។

25. ដូច្នេះ មេធាវីការពារក្ដីសន្និដ្ឋានថា [redacted] (សាក្សី ង) នឹងអាចមានលទ្ធភាពរៀបរាប់រឿងរ៉ាវដែលបានជួបផ្ទាល់អំពីការបះបោរទាំងនោះ និងការដាក់ពន្ធនាគារកម្មាភិបាលភូមិភាគបូព៌ាជាមួយនឹងរូបគាត់នៅតាមមន្ទីរសន្តិសុខនាពេលក្រោយមករួមទាំងមន្ទីរសន្តិសុខ ស-២១ ផងដែរ។ គាត់អាចផ្ដល់ការយល់ដឹងដោយជួបផ្ទាល់ និងមានតម្លៃខ្លាំងអំពីការរៀបចំការបះបោរ ព្រមទាំងការចូលរួម និងការបង្ក្រាបកម្មាភិបាលភូមិភាគបូព៌ានៅក្នុងហេតុការណ៍នោះផងដែរ។

---

[47] កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] (សាក្សី ឃ)" ERN 01247893។

[48] ឯកសារ **E3/2961R** និងឯកសារ **E3/2962R** "កិច្ចសម្ភាសន៍ [redacted] ដោយ Ben Kiernan ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៩២" កាសែតផ្នែក ក និងកាសែតផ្នែក ខ ត្រូវបានធ្វើប្រតិចារិត និងបកប្រែទៅជាភាសាអង់គ្លេសនៅក្នុងឯកសារ **E3/1568** "អត្ថបទវាយឡើងវិញពីកិច្ចសម្ភាសន៍សរសេរដោយដៃជាមួយនឹង ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩១ និង [redacted] ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩២" (កិច្ចសម្ភាសន៍របស់ Kiernan ជាមួយនឹង ជា [redacted]) ERN 0065862-907។ "មេបញ្ជាការកងទ័ពនៅខាងជើងផ្លូវជាតិគឺ ប៉ុល សារឿន សុង នាថ មៅ ផុក សោ ណាល់។ តានីយ៉ា គឺជាមន្ត្រីតំបន់ជាស៊ីវិល ផ្នែកសន្តិសុខនៅខាងត្បូងផ្លូវជាតិ។ និងកងវរសេនាតូចដែលដឹកនាំដោយ សែ ឈុន និង [redacted]" ERN 00651902។

[49] ឯកសារ **E319/43.3.1** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត [redacted] ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ERN 00947224។

26. សក្ខីកម្មរបស់សាក្សី [redacted] (សាក្សី ង) ហាក់ដូចជាមានលក្ខណៈពាក់ព័ន្ធ ដោយសារថា មានតែសាក្សីម្នាក់គត់គឺសាក្សី មាស សឿន ដែលត្រូវបានអង្គជំនុំជម្រះជ្រើសរើសឲ្យមកផ្តល់សក្ខីកម្មទាក់ទងនឹង "ការបោសសម្អាត" ដែលបានកើតឡើងនៅភូមិភាគបូព៌ា[50]។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មាស សឿន បម្រើការងារជាអនុប្រធានរោងក្រឡឹងនៅក្នុងតំបន់ ២១។ គាត់ក៏ជាកូនប្រុសរបស់ មាស សេងហុង ហៅ ចាន់ ដែលគឺជាអនុប្រធានភូមិភាគបូព៌ាផងដែរ តែក្រោយមកបានក្លាយទៅជាលេខាតំបន់ ២៣ និង ២៤។ ក៏ប៉ុន្តែ លក្ខណៈពិសេសជាងគេនេះគឺសក្ខីកម្មផ្ទាល់របស់ មាស សឿន ដែលបានលើកឡើងថា គាត់មិនបានដឹងអំពីស្ថានភាពនៅថ្នាក់លើៗ និងការបះបោរដែលដឹកនាំដោយក្រុម សោ ភឹម ប្រឆាំងនឹងមជ្ឈិមទេ[51]។ [redacted] (សាក្សី ង) មានឋានន្តរសក្តិខ្ពស់ជាង និងបានចូលរួមកិច្ចប្រជុំយ៉ាងហោចណាស់ម្តងដែលបានរៀបចំឡើងដោយមេដឹកនាំនៃក្រុមបះបោរភូមិភាគបូព៌ា។ ស ខេង អាចផ្តល់សក្ខីកម្មសំខាន់ជាងអំពីការតស៊ូផ្ទៃក្នុងដែលនាំឲ្យមាន "ការបោស សម្អាត" នៅកន្លែងនោះ។

## ឃ. សាក្សីថ្មីម្នាក់មកផ្តល់សក្ខីកម្មអំពីក្រុមជម្លោះផ្ទៃក្នុងនៅតាមព្រំដែនថៃពាក់ព័ន្ធនឹងផ្នែក "បោសសម្អាតផ្ទៃក្នុង"

### *(i)* [redacted] *(សាក្សី ច)*

27. [redacted] (សាក្សី ច) គឺជាកងទ័ពនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[52]។ គាត់លើកឡើងថា នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៧ គាត់ឈរជើងនៅភូមិផ្លូកក្នុងខេត្ត

---

[50] នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ឈុន សាម៉ន បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹង "ការបោសសម្អាត" នៅក្នុងភូមិភាគបូព៌ា។ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីពុំផ្តល់សក្ខីកម្មក្រោមសម្បថ មេធាវីការពារសូមបង្ហាញជំហរថា ភ័ស្តុតាងរបស់ពួកគេមិនគួរត្រូវបានផ្តល់ទម្ងន់ដូចនឹងសក្ខីកម្មរបស់សាក្សីនោះទេ។

[51] *សូមមើល ឧ.* សេចក្តីព្រាងប្រ. (មាស សឿន) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ទំព័រ ៩៧ ជួរ ២៣-២៥ (សាក្សីពុំបានដឹងថាតើនរណាជា ហេង សំរិន នៅពេលនោះទេ, ទំព័រ ៩៨ ជួរ ៤-៨ (សាក្សីពុំបានដឹងថាតើនរណាជា ចាន់ ចក្រី នៅពេលនោះឡើយ)។ សេចក្តីព្រាងប្រ. (មាស សឿន) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ទំព័រ ១៤ ជួរ ១ (សាក្សីពុំបានស្គាល់នរណាម្នាក់មកពីសេនាធិការនៃភូមិភាគបូព៌ានោះឡើយ), ទំព័រ ១៥ ជួរ ៥-៩ (សាក្សីមិនដែលឮ "ការតស៊ូសម្ងាត់នៅក្នុងភូមិភាគបូព៌ាដែលដឹកនាំដោយ សោ ភឹម [និង] ហេង សំរិន នោះឡើយ")។

[52] ឯកសារ **E3/9009** "កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted]" ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០ ("កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted]") ERN 01236297-316។

ឧត្តរមានជ័យ ពោលគឺ ៣,៤ គីឡូម៉ែត្រពីព្រំដែនថៃ-កម្ពុជាប្រជាធិបតេយ្យ[53] ដែលនៅទីនោះគាត់ទទួលបន្ទុកការពារព្រំដែន និងទប់ស្កាត់កុំឱ្យជនស៊ីវិលចូលប្រទេសថៃ[54]។ គាត់លើកឡើងថា មានពេលមួយនៅក្នុងឆ្នាំ១៩៧៧ មេដឹកនាំកងរបស់គាត់ម្នាក់ឈ្មោះ យឿន យ៉ុង ដែល "ដឹកនាំក្រុមបះបោរមានឈ្មោះថា សេរីកា ដើម្បីប្រឆាំងនឹងខ្មែរក្រហម"[55] បានធ្វើឱ្យប្រជាជនដែលត្រូវបានចាប់ខ្លួននៅ សាយសាម៉ន ភូមិភាគពាយ័ព្យរត់គេចខ្លួនរួចទៅជាមួយនឹងពួកគេទៅប្រទេសជិតខាង គឺ ប្រទេសថៃ[56]។

28. ដូច្នេះ [redacted] (សាក្សី ច) អាចផ្តល់ភ័ស្តុតាងសំខាន់អំពីការបះបោរនៅភូមិភាគពាយ័ព្យ និងជាពិសេស អំពីក្រុមរៀបចំក្បត់សេរីការ។

**ខ. សាក្សីមួយរូបនឹងផ្តល់សក្ខីកម្មអំពីតួនាទីរបស់កងវរសេនាធំពិសេស ៧០៤ និងមូលដ្ឋាននៃការចាប់ខ្លួន**

***(i)*** [redacted] ***(សាក្សី ឆ)***

29. នៅឆ្នាំ ១៩៧៦ [redacted] (សាក្សី ឆ) បានចូលក្នុងកងពិសេស ៧០៤ នៅក្នុងកងពល ៧០៣ ហើយបន្ទាប់មកទៀត ត្រូវបានបញ្ជូនទៅ កងកាត់ដេរ ៥៧[57]។ [redacted] (សាក្សី ឆ) ពន្យល់ថា កងពិសេស ៧០៤ ត្រូវបានចាត់តាំងឡើងដើម្បីតាមដានកម្មករនៅរោងចក្រ ដើម្បីកំណត់រកជនក្បត់: គេ "ឱ្យទៅបង្កប់ស្រាវជ្រាវរកខ្មាំងផ្ទៃក្នុង"[58]។

30. ដំណើរការត្រួតពិនិត្យដែលរៀបរាប់ដោយ [redacted] (សាក្សី ឆ) គឺចង្អុលបង្ហាញភស្តុតាងនៃការអះអាងរបស់មេធាវីការពារក្តីថា ការចាប់ខ្លួនភាគច្រើន ដែលបានធ្វើឡើងនោះ គឺធ្វើឡើងតាមទំនើងចិត្ត។

---

[53] **E3/9009** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ERN 01236297។

[54] **E3/9009** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ERN 01236302។

[55] **E3/9009** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ERN 01236303។

[56] **E3/9009** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ERN 01236303។

[57] កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ERN 01236303 ភាសាខ្មែរ 01247827។

[58] កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ERN 01236303 ភាសាខ្មែរ 01247838។

## ច. សាក្សីពីររូបនឹងផ្ដល់សក្ខីកម្មនៅលើការដោះលែងអ្នកទោសពីមន្ទីរសន្តិសុខ ស២១

31. ដោយអនុលោមតាមអំណះអំណាងដែលបានរៀបរាប់ខាងលើ[59] សាក្សីពីររូបនៅខាងក្រោមនឹងផ្ដល់អំពីសភាពពិតប្រាកដនៃដំណើការនៅស២១។

*(i)* [redacted] *(សាក្សី ជ)*

32. [redacted] (សាក្សី ជ) គឺជាពេទ្យនៅក្នុងកង៤ នៃកងពល ៣១០ នៅក្រោមការគ្រប់គ្រងរបស់អឿន[60]។ នៅបន្ទាប់ពីឆ្នាំ ១៩៧៥ គាត់នៅពេទ្យ ព្រះកេតុមាលា នៅភ្នំពេញ ដែលជាមន្ទីរពេទ្យរបស់កងពល ៣១០[61]។ នៅខែ ធ្នូ ឆ្នាំ ១៩៧៦ បន្ទាប់ពីការចាប់ខ្លួនប្រធានពេទ្យឈ្មោះ ផែន និងប្រធានកងពល អឿង រួចមក[62] [redacted] (សាក្សី ជ) ត្រូវបានបានចាប់ខ្លួន និងបញ្ជូនទៅស២១[63]។ [redacted] (សាក្សី ជ) និយាយថា គាត់ស្នាក់នៅ "មន្ទីរសន្តិសុខទួលស្លែង" ចំនួនពីរថ្ងៃមុនពេលត្រូវបានដោះលែង ដោយមានការអន្តរាគមន៍ពីអនុប្រធានមន្ទីរពេទ្យកេតុមាលាឈ្មោះ យាត[64]។ នៅខែ មីនា ឆ្នាំ ១៩៧៧ គាត់ត្រូវបានបញ្ជូនទៅ "លត់ដំ" នៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[65]។

33. នៅខែ កុម្ភៈ ឆ្នាំ ១៩៧៨ [redacted] (សាក្សី ជ) បានផ្លាស់ប្ដូរមកធ្វើការវិញនៅកងពេទ្យលេខ៤ ដោយសារតែគាត់បានកែខ្លួនរួចហើយ[66]។

*(ii)* [redacted] *(សាក្សី ឈ)*

34. [redacted] (សាក្សី ឈ) គឺជាទាហានកងពល ៥០២។ នៅក្នុងកិច្ចសម្ភាសន៍របស់ DC-Cam គាត់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសតូចតាច និងត្រូវបានបញ្ជូនទៅមន្ទីស២២ ដែលជាមន្ទីរ

---

[59] សូមមើល កថាខណ្ឌ ៣ ដល់ ៥ ខាងលើ។

[60] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251253។

[61] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251252។

[62] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251252-53។

[63] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251254។

[64] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251254។

[65] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251255។

[66] **E3/7537** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00251257។

សន្តិសុខរបស់កងពល ៥០២[67]។ នៅខែ មីនា ឬ មេសា ឆ្នាំ ១៩៧៧[68] [redacted] (សាក្សី ឈ) ត្រូវបានបញ្ជូនពី ស២២ ទៅ ស ២១ ដែលគាត់ត្រូវបានជាប់ឃុំឃាំងរយៈពេលពីរខែកន្លះ នៅមុនពេលដែលត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង[69]។ [redacted] (សាក្សី ឈ) និយាយបន្ថែមទៀតថា គាត់ត្រូវបានដោះលែងពីមន្ទីរស២១ ជាមួយមនុស្ស "ប្រហែលជា៥០នាក់"[70]។

35. [redacted] (សាក្សី ឈ) បានផ្តល់សក្ខីកម្មចំនួនពីរជូនសហចៅក្រមស៊ើបអង្កេត គឺនៅបន្ទាប់ពីរយៈពេលប្រាំមួយ និងប្រាំពីរឆ្នាំបន្ទាប់ពីការសម្ភាសន៍របស់គាត់លើកដំបូងជាមួយ DC-Cam[71] ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងនេះមិនត្រូវបាននិយាយអំពីពេលវេលា ដែលគាត់នៅស២១ នោះទេ។ សក្ខីកម្មក្នុងសវនាការរបស់ [redacted] (សាក្សី ឈ) នឹងជាឱកាសមួយសម្រាប់បញ្ជាក់អំពីបទសម្ភាសន៍លើកដំបូងរបស់គាត់ និងទទួលបាននូវរឿងរ៉ាវលម្អិតបន្ថែមទៀតអំពីការងារនៅមន្ទីរ ស២១ និងការដោះលែងអ្នកទោសពីមន្ទីរសន្តិសុខ។

36. [redacted] (សាក្សី ឈ) នឹងអាចផ្តល់ព័ត៌មានសំខាន់ផងដែរទាក់ទងនឹងការបះបោរ និងជម្លោះផ្ទៃក្នុង។ ជាការពិតណាស់ នៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយ DC-Cam គាត់រៀបរាប់អំពីការប្រជុំមួយចំនួននៅស្តាតអូឡាំពិចដែលចូលរួមដោយទាហានទាំងអស់របស់សេនាធិការនៅចុងឆ្នាំ ១៩៧៦ ឬក៏ដើមឆ្នាំ ១៩៧៧ ហើយដែលខ្លួនគាត់បានចូលរួមប្រជុំដែរ[72]។ គាត់បានរៀបរាប់អំពីការចាប់ខ្លួនថានៅបន្ទាប់ពីការប្រជុំដែលមានការចាប់ខ្លួន ចាន់ ចក្រី និង មេបញ្ជាការផ្សេងទៀតដែលត្រូវបានចោទថាក្បត់[73]។

## ឃ. ឯកសារចំនួនបួនដែលត្រូវទទួលយកធ្វើជាភស្តុតាង

### *(i) សេចក្តីសង្ខេបនៃឯកសារ*

[67] **E3/7532** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] ថ្ងៃទី ២៤ តុលា ឆ្នាំ ២០០៣ EN 00329467។

[68] **E3/7532** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00329482។

[69] **E3/7532** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00329478។

[70] **E3/7532** កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង [redacted] EN 00329481។

[71] **E3/5263** កំណត់ហេតុស្តាប់ចម្លើយ [redacted] ថ្ងៃទី ៦ មករា ២០០៩ EN 00282222-225។ និង **E3/8739**កំណត់ហេតុស្តាប់ចម្លើយ [redacted] ថ្ងៃទី ១ ធ្នូ ២០១០ EN 00630429-436។

[72] **E3/5263** កំណត់ហេតុស្តាប់ចម្លើយ [redacted] EN 00282224។

[73] **E3/5263** កំណត់ហេតុស្តាប់ចម្លើយ [redacted] EN 00282224។

37. ក្រៅពីសាក្សីខាងលើ មេធាវីការពារក្តីស្នើសុំឱ្យទទួលយកឯកសារខាងក្រោមធ្វើជាភ័ស្តុតាង។ ភាគីអាចបើកមើលឯកសារទាំងនោះបាននៅក្នុងថតផ្ទុកឯកសាររួម។

| **ភាពពាក់ព័ន្ធ** | **ERN** | **កាលបរិច្ឆេទ** |
|---|---|---|
| កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងសាក្សី [redacted] (សាក្សី ក) | KH: 01247800-01247820 | ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០០ |
| កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងសាក្សី [redacted] (សាក្សី ខ) | EN: 01302704-01302719<br>KH: 01247665-01247688 | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០១ |
| កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងសាក្សី [redacted] (សាក្សី គ) | KH: 01247745-01247765<br>EN: 01302752-01302766 | ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០១ |
| កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងសាក្សី [redacted] (សាក្សី ឃ) | KH: 01247880-01247905<br>EN: 01303938-01303956 | ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ |
| កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងសាក្សី [redacted] (សាក្សី ឆ) | KH: 01247821-01247839<br>EN: 01303924-01303937 | ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០១ |

*(ii)* ***ឯកសារដែលស្នើសុំឱ្យទទួលយក តាមការវិភាគបឋម មានភាពពាក់ព័ន្ធ និងគួរឱ្យជឿជាក់បាន***

38. ឯកសារដែលស្នើសុំនេះគឺពាក់ព័ន្ធដោយផ្ទាល់ *នៅក្នុងចំណោមនោះ* ការចោទប្រកាន់អំពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៧៨ ដល់ ២០៤, ៤១៥ ដល់ ៤៧៥ និង ៥៨៩ ដល់ ៦៤៣ នៃដីកាដំណោះស្រាយ[74]។ ដោយសារថា ឯកសារដែលបានស្នើសុំគឺជាចម្លើយ ឬពាក់ព័ន្ធនឹងសាក្សីដែលបានស្នើសុំនៅក្នុងសំណើនេះ ដែលត្រូវបានសម្ភាសន៍ដោយអង្គការដ៏មានកេរ្តិ៍ឈ្មោះមួយ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា មេធាវីការពារក្តីសន្និដ្ឋានថា ចម្លើយទាំងអស់ដែលបានស្នើសុំ អាចទុកចិត្តបាន និងមាន ភាពពាក់ព័ន្ធ*ជាបឋម* ទៅនឹងសំណុំរឿង ០០២/០២ ។

## ខ. សំណើសុំបានដាក់ទាន់ពេលវេលាកំណត់

39. ដោយហេតុថា ភាគីត្រូវបានជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សីដែល អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសរួចហើយឱ្យមកបង្ហាញខ្លួនពាក់ព័ន្ធនឹងវគ្គ "បោសសម្អាតផ្ទៃក្នុង" មេធាវីការពារក្តីបានវាយតម្លៃលក្ខណៈនៃភស្តុតាងដែលអាចទាញយកពីសាក្សីទាំងនេះ ហើយក៏បានស្រាវជ្រាវរកភស្តុតាងបន្ថែមដែលអាចពាក់ព័ន្ធនឹងរឿងក្តីនេះ។ កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានរកឃើញនៅក្នុងកិច្ចដំណើរការនីតិវិធីត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ហើយសំណើសុំនេះត្រូវបានដាក់តាំងពីដំបូង បំផុតម្ល៉េះ[75]។

40. គ្រប់កាលៈទេសៈទាំងអស់ ឯកសារដែលបានស្នើសុំទាំងអស់នេះទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះ និងជាភស្តុតាងដោះបន្ទុក។ ដូច្នេះ មេធាវីការពារក្តីអះអាងថា ការទទួលយកដាក់ឯកសារទាំងនេះចូលទៅសំណុំរឿង នឹងអាចនាំទៅដល់ការបញ្ជាក់ការពិត[76]។

---

[74] **D427** ដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។

[75] *សូមមើល* កថាខណ្ឌ ៣១ *ខាងលើ*។

[76] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ **E289**) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)" ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៖ "យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភស្តុតាងថ្មីៗនានា ដែលខ្លួនចាត់ទុកថាអាចនាំទៅដល់ការបញ្ជាក់ការពិត នៅក្នុងករណីដែលភស្តុតាងនោះបំពេញបទដ្ឋាន*តាមការពិនិត្យបឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ជាទូទៅ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលខ្លួនស្នើសុំដាក់នៅ

*សំណើលើកទីប្រាំរបស់ នួន ជា សុំកោះហៅសាក្សី*

## V. សំណូមពរ

41. យោងតាមហេតុផលដែលបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ស្នើទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឱ្យធ្វើការវាយតម្លៃពីហានិភ័យ ពាក់ព័ន្ធនឹងសាក្សី៤។

ខ. កោះហៅសាក្សី៤, [redacted] (2-TCW-971), [redacted] (សាក្សី ក), [redacted] (សាក្សី ខ) , [redacted] (សាក្សី គ) , [redacted] (សាក្សី ឃ), [redacted] (សាក្សី ច), [redacted] (សាក្សី ឆ), [redacted] (សាក្សី ជ) និង [redacted] (សាក្សី ឈ) ឱ្យមក ផ្តល់សក្ខីកម្មនៅក្នុងវគ្គសវនាការស្តីអំពីមន្ទីរសន្តិសុខ និង "ការបោសសំអាតផ្ទៃក្នុង"។

គ. ទទួលយកឯកសារនានាដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ ៣៨ ដែលនៅពេលនេះមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម យកធ្វើជាភស្តុតាងក្នុងសំណុំរឿង ០០២/០២។

**សហមេធាវីការពារក្តីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**

---

ចំពោះមុខអង្គជំនុំជម្រះ ពុំអាចរកបាននៅមុនពេលបើកសវនាការ ឬពុំអាចត្រូវបានរកឃើញដោយមានការយកចិត្តទុកដាក់សមស្រប។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលពុំបានបំពេញឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌនេះ រួមមាន ក្នុងករណីដែលភស្តុតាង ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលភស្តុតាងដែលបានស្នើសុំដាក់នេះ ជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីបញ្ចៀសនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ ឬក្នុងករណីដែលភាគីដទៃទៀតពុំជំទាស់ទៅនឹងភស្តុតាងនោះ"។